ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៥៣៧

ចុះថ្ងៃទី ២៨_០៦_២០១២

<u>សាលដីកាព្រហ្មទណ្ឌ</u>

លេខ : ៥៦ "ក្រ.II សទ"

ចុះថ្ងៃទី ១៩_០៧_២០១៣

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្តី ដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ ០៦ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩៣ បានបើកសវនាការជាសាធារណៈនៅសាលសវនាការសាលាឧទ្ធរណ៍ នាថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៣ ដោយមានសមាសភាពដូចខាងក្រោម:

**<u>ក្រុមប្រឹក្សាជំនុំជម្រះ</u>**

- ឯកឧត្តម [redacted] ជាប្រធាន
- លោក [redacted] ជាចៅក្រមប្រឹក្សា
- លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

**ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ ៥៣៧ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១២ ដែលមាន:**

១- ជនជាប់ចោទឈ្មោះ [redacted]រិន ភេទប្រុស អាយុ ២៣ឆ្នាំ ជាតិខ្មែរ មុខរបរកម្មករសំណង់ កើតនៅភូមិគិរីមានជ័យ ឃុំគិរីមានជ័យ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ទីលំនៅសព្វថ្ងៃ[redacted]សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] (រ) ម្តាយឈ្មោះ[redacted] (រ) ទោសពីមុនគ្មាន (**ដើមបណ្តឹងឧទ្ធរណ៍**) ។

២- ជនជាប់ចោទឈ្មោះ [redacted] **ហេង** ភេទប្រុស អាយុ ២២ឆ្នាំ ជាតិខ្មែរ មុខរបរលក់ថ្នាំដុសធ្មេញ កើតនៅភូមិពកក្រុណ ឃុំពោធិ៍ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ទីលំនៅសព្វថ្ងៃ[redacted] សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted] (រ) ម្តាយឈ្មោះ [redacted]) នៅលីវ ទោសពីមុនគ្មាន (**ដើមបណ្តឹងឧទ្ធរណ៍**) ។

៣- ជនជាប់ចោទឈ្មោះ[redacted] **សារ៉េត ហៅ គ្រេត** ភេទប្រុស អាយុ ២៦ឆ្នាំ ជាតិខ្មែរ កើតនៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ [redacted] ក្រុមទី ៦ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]រ) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] មានកូន ១នាក់ គេចខ្លួន ។

**ជាប់ចោទពីបទៈ** **លួចដោយមានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចផ្សារឯករាជ្យ ១ ផ្ទះលេខ ៤៥D ភូមិត្រពាំងឈូក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ខាងឃីម** ទីលំនៅសព្វថ្ងៃផ្ទះលេខ ៤៥D ភូមិត្រពាំងឈូក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ**

កាលពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១១ វេលាម៉ោង ១ និង៣០នាទី យប់ ឈ្មោះ[redacted] **រិន** ឈ្មោះ [redacted] **ហេង** និងឈ្មោះ [redacted] **សារ៉េត** និងបក្សពួក បានផ្តើះសោរបន្ទប់លួចសម្ភារៈរបស់ឈ្មោះ [redacted] **ខាងឃីម** ខណៈពេលដែលឈ្មោះ [redacted] **ខាងឃីម** ដេកលក់ នៅចំណុចផ្ទះលេខ ៤៥D ភូមិត្រពាំងឈូក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ លុះឈ្មោះ [redacted] **ខាងឃីម** ភ្ញាក់ឡើងក៏ប្តឹងសមត្ថកិច្ច ហើយឃាត់ខ្លួនបានឈ្មោះ [redacted] **រិន** និងឈ្មោះ [redacted] **ហេង** ចំណែកឈ្មោះ [redacted] **សារ៉េត** និងបក្សពួកមួយចំនួនទៀតគេចខ្លួនបាត់។

**បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២១ ក្រ៦ ភ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ**

១- **ផ្តន្ទាទោសឈ្មោះ**[redacted]**រិន** ភេទប្រុស អាយុ ២៣ឆ្នាំ ឈ្មោះ [redacted] **ហេង** ភេទប្រុស អាយុ ២២ឆ្នាំ ឈ្មោះ [redacted] **សារ៉េត ហៅ គ្រេត** ភេទប្រុស អាយុ ២៦ឆ្នាំ ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់ចំនួន ៥ឆ្នាំ (ប្រាំឆ្នាំ) ពីបទ **លួចដោយមានស្ថានទម្ងន់ទោស ការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចផ្សារឯករាជ្យ ១ ផ្ទះលេខ ៤៥D ភូមិត្រពាំងឈូក សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២- បង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] **សារ៉េត ហៅ គ្រេត** តាមអំណាចនៃសាលក្រមតាមមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ។

៣- សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១២ នៅសាលាដំបូងរាជធានីភ្នំពេញ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **រិន** និងឈ្មោះ [redacted] **ហេង** កំបាំងមុខជនជាប់ចោទឈ្មោះ[redacted]**សារ៉េត** ទុកសិទ្ធិប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

- បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] **រិន** ជាជនជាប់ចោទ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២១ ក្រ៦ ភ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

- បានឃើញ សេចក្ដីចម្លងបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] ហេង ជាជនជាប់ចោទ ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២១ ក្រ៦ ភ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

- បានឃើញរបាយការណ៍រឿងព្រហ្មទណ្ឌរបស់ចៅក្រមរបាយការណ៍ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ។

**នាពេលសវនាការ**

- ជនជាប់ចោទឈ្មោះ [redacted] រ៉ន (វត្តមាន)

- ជនជាប់ចោទឈ្មោះ [redacted] ហេង (អវត្តមាន)

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ខាងឃីម (អវត្តមាន)

ជនជាប់ចោទឈ្មោះ [redacted] **រ៉ន** ឆ្លើយថាៈ កាលពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១១ ខ្លួនដេកនៅផ្ទះរបស់ឈ្មោះ [redacted] **សារ៉េត** ឈ្មោះ **ហ៊ួយ** និងឈ្មោះ **ចិន** ឈ្មោះ [redacted] **ហេង** ក៏ដេកនៅទីនោះដែរ ខ្លួនកំពុងតែដេកឃើញឈ្មោះ [redacted] **ហេង** និងឈ្មោះ **គ្រេត** ជញ្ជូនឥវ៉ាន់មាន ទូរទស្សន៍ កង្ហា និងចានឆ្នាំងចូលក្នុងផ្ទះដែលខ្លួនដេក ហើយខ្លួនសួរថា បានមកពីណា ឈ្មោះ [redacted] **ហេង** ឆ្លើយថា កុំចេះដឹង ។ ក្រោយមកអ្នកទាំងនោះដាស់ខ្លួនឱ្យក្រោកឡើង ខ្លួនចុះមកក្រោមម្នាក់ឯង ពេលនោះអ្នកភូមិ និងសមត្ថកិច្ចឃាត់សួរ និងប្រាប់ខ្លួនថា មានគេគាស់ផ្ទះ ខ្លួនបានប្រាប់សមត្ថកិច្ចថា ខ្លួនពុំបានចូលរួមចំពោះហេតុការណ៍នេះ ខ្លួនពុំបានចូលរួមប្រព្រឹត្តទេ ។ សំណូមពរ សូមសាលាឧទ្ធរណ៍មេត្តាសម្រេចឱ្យខ្លួនរួចផុតពីបទចោទប្រកាន់ ។

**តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ធ្វើសេចក្ដីសន្និដ្ឋានថាៈ** មានភស្តុតាងដាក់បន្ទុកលើជនជាប់ចោទ ឈ្មោះ [redacted] **ហេង** និងឈ្មោះ **គ្រេត** ([redacted] **សារ៉េត**) ដូចបទចោទប្រកាន់របស់អយ្យការប្រាកដមែន ។ ភស្តុតាងនោះ គឺចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **រ៉ន** បានឆ្លើយថា ខ្លួនឃើញឈ្មោះ [redacted] **ហេង** និងឈ្មោះ **គ្រេត** ជញ្ជូនឥវ៉ាន់មានទូរទស្សន៍ កង្ហា និងចានឆ្នាំងចូលមកក្នុងផ្ទះដែលខ្លួនដេក ហើយខ្លួនសួរថា បានពីណាមក ឈ្មោះ [redacted] **ហេង** ឆ្លើយថា កុំចេះដឹង ខ្លួនក៏ដេកបន្ត ។ ពុំមានភស្តុតាងដាក់បន្ទុកលើឈ្មោះ [redacted] **រ៉ន** ដូចបទចោទប្រកាន់របស់អយ្យការនោះឡើយ ហេតុនេះ គប្បីសភាព្រហ្មទណ្ឌធ្វើការពិចារណាឡើងវិញ ។

សំអាងហេតុ និងសេចក្ដីសម្រេចនៃសាលក្រមព្រហ្មទណ្ឌលេខ ២១ ក្រ៦ ភ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ មានលក្ខណៈត្រឹមត្រូវ គប្បីសភាព្រហ្មទណ្ឌពិចារណាឡើងវិញត្រង់ចំណុចផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **រ៉ន** ។

- ក្រោយពីបានស្ដាប់អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] **រ៉ន**

- ក្រោយពីបានស្ដាប់អំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] **ហេង**

- ក្រោយពីបានស្ដាប់អំណានចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី

- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍

- ក្រោយពីបានពិនិត្យពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ ។

## សភាព្រហ្មទណ្ឌ យល់ឃើញថា

១- បណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] **រិន** និងឈ្មោះ [redacted] **ហេង** ជាជនជាប់ចោទ ប្ដឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២១ ក្រ៦ ភ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច បានធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ សភាព្រហ្មទណ្ឌទទួលជំនុំជម្រះបាន យោងតាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២- នាពេលកិច្ចពិភាក្សាដេញដោល ជនជាប់ចោទឈ្មោះ [redacted] **រិន** បានឆ្លើយថា កាលពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១១ ខ្លួនដេកនៅផ្ទះរបស់ឈ្មោះ [redacted] **សារ៉េត** ឈ្មោះ **ហ៊ួយ** និងឈ្មោះ **ចិន** ឈ្មោះ [redacted] **ហេង** ក៏ដេកនៅទីនោះដែរ ខ្លួនកំពុងតែដេកឃើញឈ្មោះ [redacted] **ហេង** និងឈ្មោះ **គ្រេត** ជញ្ជូនឥវ៉ាន់មាន ទូរទស្សន៍ កង្ហា និងចានឆ្នាំងចូលក្នុងផ្ទះដែលខ្លួនដេក ហើយខ្លួនសួរថា បានមកពីណា ឈ្មោះ [redacted] **ហេង** ឆ្លើយថា កុំចេះដឹង ។ ក្រោយមកអ្នកទាំងនោះដាស់ខ្លួនឱ្យក្រោកឡើង ខ្លួនចុះមកក្រោមម្នាក់ឯង ពេលនោះអ្នកភូមិ និងសមត្ថកិច្ចឃាត់សួរ និងប្រាប់ខ្លួនថា មានគេគាស់ផ្ទះ ខ្លួនបានប្រាប់សមត្ថកិច្ចថា ខ្លួនពុំបានចូលរួមចំពោះហេតុការណ៍នេះ ខ្លួនពុំបានចូលរួមប្រព្រឹត្តទេ។ ឃើញថា ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **រិន** គ្រាន់តែជាចម្លើយដោះសារយករួចខ្លួនប៉ុណ្ណោះ ដែលតុលាការមិនអាចជឿបានឡើយ តែតាមការអង្កេត និងតាមរបាយការណ៍សំយោគលេខ ០៨៥/១១ របក ចុះថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ២០១១ របស់អធិការដ្ឋាននគរបាលខណ្ឌដង្កោបានបញ្ជាក់ថា ជនជាប់ចោទឈ្មោះ [redacted] **ហេង** ឈ្មោះ [redacted] **រិន** និងឈ្មោះ [redacted] **សារ៉េត ហៅ គ្រេត** ពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តហិង្សា កាលពីថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១១ ពិតមែន។ ឃើញថា ជាអំពើមានធាតុផ្សំ និងពិរុទ្ធភាពគ្រប់គ្រាន់ដាក់បន្ទុកលើជនជាប់ចោទ ពីបទ **លួចដោយមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ដូចមានក្នុងផ្នែកសំអាងហេតុនៃសាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញបញ្ជាក់ស្រាប់។ សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុទាំងនេះ។ ហេតុដូច្នេះ សភាព្រហ្មទណ្ឌមិនចាំបាច់លើកយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតទេ។

៣- សាលក្រមព្រហ្មទណ្ឌលេខ ២១ ក្រ៦ ភ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ហើយ ដែលគប្បីសភាព្រហ្មទណ្ឌតម្កល់ទុកជាបានការដដែល ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១- ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] រិន និងឈ្មោះ [redacted] ហេង ជាជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២១ ក្រ៦ ភ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១២ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការ ។

៣- បន្តឃុំខ្លួនជនជាប់ចោទឈ្មោះ [redacted] រិន និងឈ្មោះ [redacted] ហេង តាមនីតិវិធីច្បាប់ ។

៤- សាលដីកានេះជំនុំជម្រះនៅថ្ងៃទី ១១ ខែកក្កដា ឆ្នាំ២០១៣ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] រិន កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហេង និងដើមបណ្តឹងរដ្ឋប្បវេណី និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៩ ខែកក្កដា ឆ្នាំ២០១៣ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] រិន តែចាត់ទុកជាចំពោះមុខ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ហេង និងដើមបណ្តឹងរដ្ឋប្បវេណី ។

បើកសិទ្ធិប្តឹងតវ៉ាក្នុងកំណត់ច្បាប់ ។

សាលដីកានេះចូលជាស្ថាពរមានអានុភាពអនុវត្តតែលើឈ្មោះ [redacted] រិន ក្រៅពីនោះពុំមានអានុភាពអនុវត្តឡើយ ។

សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់ ។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

---

បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី ២៦ ខែ ០២ ឆ្នាំ ២០១៤

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានសាលាឧទ្ធរណ៍

[redacted]